N. 5
08. 2. 02

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២១-០១-២០០២ | ព្រះរាជក្រឹត្យនស/រកត/០១០២/០១៤ស្តីពីការតែងតាំងចៅក្រម ព្រះរាជ អាជ្ញា និងព្រះរាជអាជ្ញារង | ២៧៥ |
| ៣១-០១-២០០២ | ព្រះរាជក្រឹត្យ នស/រកត/០១០២/០២៣ ស្តីពីការបញ្ឈប់អាណត្តិ ឯកឧត្តម **ម៉ុក យុទ្ធា** ពីទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា | ២៧៨ |
| ០២-០២-២០០២ | ព្រះរាជក្រឹត្យ នស/រកត/០២០២/០២៦ ស្តីពីការតែងតាំង ឯកឧត្តម **ទណ្ឌ សុផាណ្ណា** ជា ឧកញ៉ា | ២៧៩ |
| ០២-០២-២០០២ | ព្រះរាជក្រឹត្យ នស/រកត/០២០២/០២៨ ស្តីពីការ ដាក់ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌសាធារណរដ្ឋបាល មន្ត្រីថ្នាក់ដឹកនាំ សមាជិក ក្រុមប្រឹក្សាធម្មនុញ្ញ និងសមាជិករដ្ឋសភា ដូចមានរាយនាមខាង ក្រោម: | ២៨០ |


## II-រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


| | | |
|---|---|---|
| ០៥-០២-២០០២ | អនុក្រិត្យលេខ ០៨អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានព័តមាន និងកិច្ចការអាស៊ាន ចំណុះក្រសួងអប់រំ យុវជននិងកីឡា | ២៨១ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការបង្កើតសាលាភូមិន្ទចៅក្រម | ២៨៣ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ១០អនក្រ.បក ស្តីពីការកំណត់ទីតាំងសំរាប់តំបន់ឧស្សាហកម្មនាងកុកខេត្តកោះកុង | ២៩៤ |
| ០៦-០២-២០០២ | អនុក្រឹត្យលេខ ១១អនក្រ.បក ស្តីពីការបង្កើតរាជាយស្ម័យយានកម្ពុជា ជាសហគ្រាសសាធារណៈ | ៣៩៧ |
| ០១-០២-២០០២ | អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្តីពីការបំពាក់មេដាយសហមេត្រីថ្នាក់សេនាចំនួន ០៤ គ្រឿងជូនចំពោះនាយកអង្គការទស្សនៈពិភពលោក និងជំនាញការអង្គការអន្តរជាតិ | ៣០៦ |
| ០៤-០២-២០០២ | អនុក្រឹត្យលេខ ៥០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០៨ |
| ០៤-០២-២០០២ | អនុក្រឹត្យលេខ ៥១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣១០ |

| | | |
|---|---|---|
| ០៤-០២-២០០២ | អនុក្រឹត្យលេខ ៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣១២ |
| ០៤-០២-២០០២ | អនុក្រឹត្យលេខ ៥៣ អនក្រ.តតស្តីពីការបំពាក់មេដាយការងារតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការនៃក្រសួងព្រះបរមរាជវាំងចំនួន ៨៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចឆ្នាំ ២០០១ | ៣១៣ |
| ០៤-០២-២០០២ | អនុក្រឹត្យលេខ ៥៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣១៧ |
| ០៤-០២-២០០២ | អនុក្រឹត្យលេខ ៥៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣១៨ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣១៩ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣២០ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣២១ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣២២ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣២៣ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៦១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣២៥ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣២៦ |
| ០៥-០២-២០០២ | អនុក្រឹត្យលេខ ៦៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣២៧ |
| ០៦-០២-២០០២ | អនុក្រឹត្យលេខ ៦៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣២៨ |
| ០៦-០២-២០០២ | អនុក្រឹត្យលេខ ៦៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣២៩ |
| ០៦-០២-២០០២ | អនុក្រឹត្យលេខ ៦៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣២ |
| ០៦-០២-២០០២ | អនុក្រឹត្យលេខ ៦៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៣ |
| ០៦-០២-២០០២ | អនុក្រឹត្យលេខ ៦៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៣៣៤ |
| ០៦-០២-២០០២ | អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៣៤២ |
| ០៧-០២-២០០២ | អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៥៣ |


## ២_សេចក្តីសំរេច


| | | |
|---|---|---|
| ០៤-០២-២០០២ | សេចក្តីសំរេចលេខ ០៩ សសរ ស្តីពីការផ្ទេរសិទ្ធិ | ៣៥៤ |
| ០៧-០២-២០០២ | សេចក្តីសំរេចលេខ ១០ សសរ ស្តីពីការតម្លើងកាំប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល | ៣៥៥ |
| ០៧-០២-២០០២ | សេចក្តីសំរេចលេខ ១១ សសរ ស្តីពីការតម្លើងកាំប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល | ៣៥៦ |
| ០៧-០២-២០០២ | សេចក្តីសំរេចលេខ ១២ សសរ ស្តីពីការតម្លើងកាំប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល | ៣៥៧ |

5

# គ

## III- ការងារបណ្ដាក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ១. សេចក្ដីជូនដំណឹង


| | | |
|---|---|---|
| ០១-០២-២០០២ | សេចក្ដីជូនដំណឹងលេខ ០១១ សហវ.អ ស្ដីពីការទូទាត់បំណុលថ្លៃទិញ ឬថ្លៃឈ្នួល ចលនវត្ថុ ឬ អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ | ៣៥៨ |


### ២. ប្រកាស


| | | |
|---|---|---|
| ០៤-០២-២០០២ | ប្រកាសលេខ ២០៥សហវ ស្ដីពីការតែងតាំងភ្នាក់ងារគណនេយ្យប្រចាំអាជ្ញាធរអប្សរា | ៣៦០ |
| ០៦-០២-២០០២ | ប្រកាសអន្តរក្រសួងលេខ ២០៦ សហវ ស្ដីពីការតែងតាំងភ្នាក់ងារបើកផ្ដល់សំរាប់បើក ប្រាក់បៀវត្សនិងប្រាក់អន្តរាគមន៍ ក្នុងវិស័យសង្គមកិច្ចនិងវប្បធម ជូនមន្ត្រីរាជការនៅក្រសួងផែនការ | ៣៦១ |

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០១៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានទ្រង់យល់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ១៩៩៤
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ៣០ ខែកក្កដា_ថ្ងៃទី ០៨ ខែតុលា_ថ្ងៃទី២២ ខែ តុលា_ថ្ងៃទី១៩ ខែ វិច្ឆិកា និងថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំង ៖

១_លោកស្រី ចាន់ សុទ្ធាវី ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅក្រសួងយុត្តិធម៌

២_លោក សឹង បញ្ញាឧត្តម ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅក្រសួងយុត្តិធម៌

៣_លោក សេង សិទ្ធត្ថា ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅក្រសួងយុត្តិធម៌

៤_លោក យូរ ឧត្តរា ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅក្រសួងយុត្តិធម៌

៥_លោកស្រី ជា លាង ជាព្រះរាជអាជ្ញា ហើយត្រូវទៅបំរើការងារនៅមហាអយ្យការ សាលាឧទ្ធរណ៍

៦_លោក ប៉ិត ច័ន្ទសំបូរ ជាព្រះរាជអាជ្ញា ហើយត្រូវទៅបំរើការងារនៅមហាអយ្យការ សាលាឧទ្ធរណ៍

៧_លោក ឡៀង សុថារ ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តកណ្តាល

៨_លោក គេង រតនា ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តកណ្តាល

៩_លោក អ៊ុន បូផា ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តកណ្តាល

១០_លោក ហួត ឫទ្ធី ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តកណ្តាល

១១_លោក ឌុច គីមសន ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តកំពង់ចាម

១២_លោក សួស សំអាត ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តបាត់ដំបង

១៣_លោក ស៊ុន រិទ្ធ ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តបាត់ដំបង

១៤_លោក មាស សុភក្តិ ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការក្រុងព្រះសីហនុ

១៥_លោក គន់ សីហាតេជះ ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តសៀមរាប

១៦_លោក ប៊ូ ប៊ុនហាង ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តសៀមរាប

១៧_លោក ស៊ុន ទិសាល ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តបន្ទាយមានជ័យ

១៨_លោក ជេត ខេមរា ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តបន្ទាយមានជ័យ

១៩_លោក ហ៊ាន រិទ្ធ ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តតាកែវ

២០_លោក អិន ម៉ានទិបុល ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តកំពង់ឆ្នាំង

២១_លោក ឯក ឆេងហួត ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តកំពង់ឆ្នាំង

២២_លោក ឌិន ស៊ីទុទ្ធី ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តកំពង់ធំ

២៣_លោក ទី សុទិនថាល់ ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំរើការងារនៅអយ្យការតុលាការខេត្តកំពង់ធំ

២៤_លោក លាង សួគី ជាចៅក្រម ហើយត្រូវទៅបំរើការងារនៅតុលាការខេត្តពោធិ៍សាត់

២៥-លោក ម៉ែន សាវ៉ាត ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំពេញការងារនៅអយ្យការតុលាការខេត្តពោធិសាត់

២៦-លោកម៉ែន ពេជ្រសាលី ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំពេញការងារនៅអយ្យការតុលាការខេត្តព្រៃវែង

២៧-លោក ទ្វីម សុផាន ជាចៅក្រម ហើយត្រូវទៅបំពេញការងារនៅតុលាការខេត្តក្រចេះ

២៨-លោក ព្រុំ ស៊ីថា ជាព្រះរាជអាជ្ញារង ហើយត្រូវទៅបំពេញការងារនៅអយ្យការតុលាការខេត្តក្រចេះ

២៩-លោក មៀច គ្រិស្នា ជាចៅក្រម ហើយត្រូវទៅបំពេញការងារនៅតុលាការខេត្តស្វាយរៀង

៣០-លោក សុខ គល្យាណ ជាចៅក្រម ហើយត្រូវទៅបំពេញការងារនៅតុលាការខេត្តស្ទឹងត្រែង

៣១-លោក យ៉ះ ណារិន ជាចៅក្រម ហើយត្រូវទៅបំពេញការងារនៅតុលាការខេត្តរតនៈគិរី

លោក លោកស្រី ដែលមានឈ្មោះដូចខាងលើនេះ ត្រូវបំពេញកម្មសិក្សារយៈពេល ២ ឆ្នាំ គាប់ពីថ្ងៃតែងតាំងនេះតទៅ ។

មាត្រា២: បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងនាយក រដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មករា ឆ្នាំ ២០០២

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

៣រល.០៤.០២.០០១៩

លេខ: ២៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០៥៣

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានបញ្ឈប់អាណត្តិ ឯកឧត្តម **ប៉ូក យូឡា** ពីទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០២

៣ស.០២.០១.០០២៩

លេខ : ២៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាន់ ណា**

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០២៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម ទណ្ណៈ សុផាណ្ណា

ជា

ឧកញ៉ា

ព្រះហស្តលេខា

នរោត្តម សីហនុ

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០០២

៣រល.០២.០២.០០៣១

លេខ : ២៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សៅ ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/ ០៤៨

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវដាក់អោយចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ មន្ត្រីថ្នាក់ដឹកនាំក្រសួង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងសមាជិករដ្ឋសភា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ហុង ថែម — រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

២- ឯកឧត្តម សរាយស ឬរី — សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

៣- ឯកឧត្តម ជិន គីមស្រេង — សមាជិករដ្ឋសភា

**មាត្រា ២ :** មន្ត្រីថ្នាក់ដឹកនាំក្រសួង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងសមាជិករដ្ឋសភា ដែលត្រូវដាក់អោយចូលនិវត្តន៍ ដូចមានរាយនាមក្នុងមាត្រា ១ ខាងលើ នៅតែបន្តការងារក្នុងមុខដំណែងនយោបាយដដែល រហូតដល់មានការសំរេចជាថ្មី ។

**មាត្រា ៣ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ : ៣០ ច.ល

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០២*

៣រល.០៤.០២.០០៣៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត នាយកដ្ឋានពត៌មាន និងកិច្ចការអាស៊ាន ចំណុះក្រសួងអប់រំ យុវជន និងកីឡា

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងអប់រំ យុវជន និងកីឡា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

### សំរេច

<u>មាត្រា១ :</u> ត្រូវបានបង្កើតនាយកដ្ឋានពត៌មាន និងកិច្ចការអាស៊ាន ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា ។

<u>មាត្រា២ :</u> នាយកដ្ឋានពតិមាន និងកិច្ចការអាស៊ានមានមុខងារ និងភារកិច្ចដូចខាងក្រោម :

-ទំនាក់ទំនងពតិមានសាធារណៈ និងការផ្សព្វផ្សាយពតិមានអប់រំ យុវជន និង កីឡា

-គ្រប់គ្រងការងារ ពត៌មានវិទ្យា (IT: InformationTechnology) និង សារគមនាគមន៍ ក្នុង វិស័យអប់រំ យុវជន និង កីឡា

-ទំនាក់ទំនងការងារអប់រំ យុវជន និង កីឡា ជាមួយក្រសួង-ស្ថាប័នជាតិ និង បណ្តាប្រទេសសមាជិកអាស៊ាន និង ស៊ីមីអូ ( SEAMEO : Southeast Asian Ministers of Education Organization ) ក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

មាត្រា៣ : នាយកដ្ឋាន ពត៌មាន និង កិច្ចការអាស៊ាន ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន មួយរូប និង អនុប្រធាននាយកដ្ឋាន មួយរូប រឺច្រើនរូប តាមការចាំបាច់ ។

មាត្រា៤ : ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់នាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា៥ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

ភ្នំពេញថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៦

-ឯកសារ/កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៩ អនក្រ.បក

# អនុក្រឹត្យ

# ស្ដីពី

# ការបង្កើតសាលាភូមិន្ទចៅក្រម

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុសញ្ញាហិរញ្ញប្បទាន ខ្មែរ-បារាំង ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ ដើម្បីអនុវត្តកម្មវិធីគាំទ្រនីតិរដ្ឋនៅកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើររបស់សមាជិកអចិន្ត្រៃយ៍ នៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតសាលាភូមិន្ទចៅក្រមមួយដែលផ្នែកបច្ចេកទេស ស្ថិតក្រោមអាណាព្យាបាលរបស់ទីស្តីការគណៈរដ្ឋ-មន្ត្រី និងផ្នែកហិរញ្ញវត្ថុ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២.-**

សាលាភូមិន្ទចៅក្រមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ហើយស្ថិតក្រោមវិសាលភាពនៃបទប្បញ្ញត្តិនៃ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

សាលាភូមិន្ទចៅក្រមមានអាសយដ្ឋាននៅផ្លូវឧកញ៉ាជូ ឡុង (ផ្លូវលេខ ៤៦៦) ខ័ណ្ឌចម្ការមន រាជធានីភ្នំពេញ ។

ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលខាងមុខ ជាសមត្ថកិច្ចរបស់សាលាភូមិន្ទចៅក្រម ។

**មាត្រា ៣.-**

សាលាភូមិន្ទចៅក្រមជ្រើសរើស និងធានារ៉ាប់រង ការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម ការបណ្តុះបណ្តាលបន្ត និងវិក្រឹត្យការចៅក្រម និងព្រះរាជអាជ្ញាដែលកំពុងបំពេញការងារនៅសាលាជម្រះក្តីនៃព្រះរាជាណាចក្រ - កម្ពុជា ។

## ជំពូកទី ២

## ការគ្រប់គ្រងសាលាភូមិន្ទចៅក្រម

**មាត្រា ៤.-**

សាលាភូមិន្ទចៅក្រម គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និងនាយកសាលា ១ រូប ដែលមានអំណាចទូលំទូលាយ ដើម្បីគ្រប់គ្រងគ្រឹះស្ថាន ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់សាលា ។

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃសាលាភូមិន្ទចៅក្រមមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- នាយកសាលាភូមិន្ទចៅក្រម | សមាជិកស្ម័យប្រវត្តិ |

៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប សមាជិក

៥- តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ១ រូប សមាជិក

៦-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ រូប សមាជិក

៧- សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ១ រូប សមាជិក

៨- ចៅក្រមតុលាការកំពូល ១ រូប សមាជិក

៩- ចៅក្រមសាលាឧទ្ធរណ៍ ១ រូប សមាជិក

១០-ចៅក្រមបារាំងជំនាញការនាយក សមាជិកអញ្ជើញ

១១-នាយកការសិក្សាសាលា សមាជិកអញ្ជើញ

សមាជិកអញ្ជើញ ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែពុំមានសិទ្ធិធ្វើការបោះឆ្នោតអនុម័តអ្វីឡើយ ។

**មាត្រា ៦.-**

នាយកសាលាភូមិន្ទចៅក្រម ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

នាយកសាលាភូមិន្ទចៅក្រម ត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ខាងតុលាការ ឬចៅក្រមខាងអយ្យការ ឬឥស្សរៈជនដែលមានសញ្ញាប័ត្រខ្ពស់ខាងនីតិសាស្ត្រ ។

នាយកសាលាមានបេសកកម្ម ÷

- ធានារ៉ាប់រងដំណើរការរបស់សាលា ដោយអនុវត្តតាមការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ធានារ៉ាប់រងការគោរពវិន័យផ្ទៃក្នុងដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង
- តំណាងសាលានៅចំពោះមុខសាលាជម្រះក្តី និងក្នុងការធ្វើលិខិតទាំងឡាយ ទាក់ទងនឹងជីវភាពស៊ីវិល
- រៀបចំថវិកា គណនីរដ្ឋបាល និងគណនីហិរញ្ញវត្ថុរបស់សាលា
- ជាអាណាប័កលើការចំណាយរបស់សាលាភូមិន្ទចៅក្រម ស្របតាមការប៉ាន់ស្មានថវិកាប្រចាំឆ្នាំ លើកលែងតែថវិកានៃមូលនិធិសាមគ្គីអាទិភាព
- រៀបចំការប្រឡងតាមគោលការណ៍ទូទៅនៃអនាមិកភាព និងកំណែពីរលើកដែលត្រូវបញ្ជាក់ក្នុងបទបញ្ជាផ្ទៃក្នុង
- តែងតាំងគ្រូបណ្តុះបណ្តាលក្រៅគ្រឹះស្ថាន និងបុគ្គលិកសាលា
- បង្កើតអង្គការលេខ និងអង្គការចាត់តាំងនៃដំណើរការ និងការគ្រប់គ្រងសាលាភូមិន្ទចៅក្រម
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ លើស្ថានភាព សីលធម៌ និងហិរញ្ញវត្ថុ និងគម្រោងការអភិវឌ្ឍរបស់សាលាជូនក្រុមប្រឹក្សាភិបាល
- ចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ទាក់ទងនិងសេវារដ្ឋបាល សហគ្រាស អង្គការវិជ្ជាជីវៈកម្ពុជា ឬ

3

បរទេស អង្គការ និងស្ថាប័នអន្តរជាតិនានា បន្ទាប់ពីការផ្តល់យោបល់ឯកភាពពីក្រុមប្រឹក្សាភិបាល និងការយល់ព្រមពីនាយករដ្ឋមន្ត្រី ។

-ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាព ព្រមទាំងដំណើរការរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលា ហើយនិងអំពីគម្រោងការអភិវឌ្ឍទាំងឡាយ ជូនដល់ក្រុមប្រឹក្សាភិបាលមុននឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ចម្លងជូនក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ៧.-**

ចៅក្រមបារាំងជាជំនាញការនាយក ទទួលបន្ទុកជួយដល់ការងារបណ្តុះបណ្តាល ក្នុងរយៈពេលអនុវត្តគម្រោងមូលនិធិសាមគ្គីអាទិភាព ។

ជំនាញការនាយក គឺជាអាណាប័កតែមួយគត់នៃមូលនិធិសាមគ្គីអាទិភាព ។

ចៅក្រមកម្ពុជា ១ រូបជានាយកសិក្សា។

មន្ត្រីជាន់ខ្ពស់មួយរូប ត្រូវតែងតាំងជាអគ្គលេខាធិការទទួលបន្ទុកការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលា ។

**មាត្រា ៨.-**

ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យ ។ កាលបើកន្លែងសមាជិកណាមួយនៅទំនេរនោះ ត្រូវតែងតាំងសមាជិកថ្មីជំនួស ។

**មាត្រា ៩.-**

ក្រុមប្រឹក្សាភិបាល ប្រជុំសម្រេចលើបញ្ហាដែលបានស្នើឡើងដោយនាយកសាលា ។ នាយកសាលា ត្រូវផ្តល់យោបល់ជាចាំបាច់ពីបញ្ហាដែលទាក់ទងដល់ការចាត់តាំង និងដំណើរការរបស់សាលា ។

ក្រុមប្រឹក្សាភិបាលមានបេសកកម្ម÷

- អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សាលា កម្មវិធីសិក្សា បែបបទនៃការប្រឡង និងសមាសភាពគណៈមេប្រយោគ
- អនុម័តគម្រោងថវិកា
- ត្រួតពិនិត្យការគ្រប់គ្រងរបស់នាយក និងអនុម័តរបាយការណ៍ប្រចាំឆ្នាំ
- អនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលសាខាជំនាញ និងយល់ព្រមលើអនុសញ្ញារវាងសាលាភូមិន្ទចៅក្រមជាមួយនិងគ្រឹះស្ថានជាតិ សេវាជាតិ ឬអន្តរជាតិនានា
- ចាត់តាំងគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ឱ្យទទួលបន្ទុកតាមដានកិច្ចការប្រចាំថ្ងៃ
- ប្រជុំពិភាក្សាលើរបាយការណ៍ប្រចាំឆ្នាំទាក់ទងនឹងសកម្មភាព ដំណើរការរដ្ឋបាល និងដំណើរការហិរញ្ញវត្ថុរបស់សាលា មុនបញ្ជូនទៅរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- តែងតាំងប្រធាន និងសមាជិកគណៈមេប្រយោគសម្រាប់ការប្រឡង។

**មាត្រា ១០.-**

ក្រុមប្រឹក្សាភិបាល ប្រជុំសាមញ្ញនៅសប្តាហ៍ទីមួយនៃខែ ឧសភា និងខែ តុលា និងប្រជុំវិសាមញ្ញតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល នាយកសាលា ឬសមាជិកក្រុមប្រឹក្សាភិបាលចំនួនពាក់កណ្តាល ។ លិខិតអញ្ជើញប្រជុំ ត្រូវភ្ជាប់របៀបវារៈប្រជុំមកជាមួយ ។

**មាត្រា ១១.-**

ក្រុមប្រឹក្សាភិបាលអាចប្រជុំបានដរាបណាមានសមាជិកចំនួនពាក់កណ្តាល ។ សេចក្តីសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើននៃសមាជិកដែលមានសិទ្ធិបោះឆ្នោតវត្តមាន ។ ក្នុងករណីដែលមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព ។

តំណាងរបស់សមាជិកក្រុមប្រឹក្សាភិបាលមិនត្រូវអនុញ្ញាតឱ្យចូលប្រជុំទេ ។

**មាត្រា ១២.-**

ការប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាទុកក្នុងបញ្ជិកាពិសេសមួយ ដែលត្រូវរក្សាទុកនៅសាលាភូមិន្ទចៅក្រម ហើយបញ្ជិកានេះ ត្រូវចុះហត្ថលេខាដោយប្រធាន និងលេខាធិការរបស់អង្គប្រជុំ ។

**មាត្រា ១៣.-**

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាភិបាលដែលចែងក្នុងមាត្រា ៩ មានសមាសភាព ៥ រូប គឺ នាយកសាលា និងសមាជិក ៤ រូបទៀតរបស់ក្រុមប្រឹក្សាភិបាល ដែលត្រូវចាត់តាំងដោយក្រុមប្រឹក្សាភិបាលក្នុងសម័យប្រជុំសាមញ្ញនៅខែឧសភា។

គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវប្រជុំរាល់សប្តាហ៍នៃចុងខែនីមួយៗ រួចត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល ។

ក្រុមប្រឹក្សាភិបាល អាចផ្ទេរឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍ នូវមុខការមួយចំនួន លើកលែងតែកិច្ចការដែលទាក់ទងនឹងថវិកាប្រចាំឆ្នាំ ការអនុម័តលើគណនី កម្មវិធីសិក្សា និងរបាយការណ៍ប្រចាំឆ្នាំ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ រាយការណ៍អំពីសេចក្តីសម្រេចរបស់ខ្លួនជូនក្រុមប្រឹក្សាភិបាលនៅក្នុងអង្គប្រជុំលើកទី ១ របស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៤.-**

សាលាភូមិន្ទចៅក្រមត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នូវឯកសារខាងក្រោម ÷

- កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់សាលាភូមិន្ទចៅក្រម
- ថវិកាប្រចាំឆ្នាំ

- របាយការណ៍នៃការគ្រប់គ្រងប្រចាំឆ្នាំ និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ

សំណុំឯកសារទាំងអស់នេះ ត្រូវផ្ញើឱ្យដល់គម្យជនក្នុងរយៈពេល ១ ខែ យ៉ាងយូរ បន្ទាប់ពីថ្ងៃប្រជុំ ។

## ជំពូកទី ៣

## ដំណើរការផ្នែកហិរញ្ញវត្ថុ

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់សាលាភូមិន្ទចៅក្រម ត្រូវស្ថិតនៅក្រោមគោលការណ៍នៃគណនេយ្យសាធារណៈ លើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យសាធារណៈដែលបានកំណត់ក្នុងមាត្រា ១២២ នៃអនុ - ក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៦.-**

នាយកសាលាភូមិន្ទចៅក្រម ជាអាណាប័កដើមខ្សែរបស់សាលា ។ ក្នុងន័យនេះនាយកសាលាត្រូវមានភារកិច្ច ៖

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

ក្នុងការចំណាយរបស់សាលា អាណាប័កដើមខ្សែអាចផ្តល់សិទ្ធិទៅឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាណាប័កដើមខ្សែអាចបង្កើតផ្នែកគ្រប់គ្រងរដ្ឋទេយ្យចំណូល និងចំណាយដោយមានការយល់ព្រមពីគណនេយ្យករប្រតិស្រុតដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

ប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់សាលាភូមិន្ទចៅក្រម ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ដូចមានចែងក្នុងមាត្រា ១៦ខាងលើ ។ គណនេយ្យករត្រូវចូលរួមការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងនាមអ្នកពិគ្រោះយោបល់ ។

**មាត្រា ១៨.-**

គណនេយ្យករត្រូវទទួលបន្ទុក ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ
- រក្សាទុក នូវលិខិតយុត្តិការ និងកាន់បញ្ជីគណនេយ្យ ។

គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះឱ្យទៅមន្ត្រីក្នុងការិយាល័យបាន ។

**មាត្រា ១៩.-**

ប្រភពធនធានរបស់សាលារួមមាន ÷

- ធនធានដំបូងដែលរដ្ឋផ្តល់ឱ្យនៅពេលចាប់ផ្តើមបង្កើតសាលា
- ឧបត្ថម្ភកធនសម្រាប់ដំណើរការ និងឧបត្ថម្ភកធនជាមូលធនដែលបានកំណត់ក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និងអច្ច័យទានដែលសាលាបានទទួល
- ផលនៃការខ្ចី
- ផលនៃការងារ តាវកាលិក និងសេវាដែលសាលាបានផ្តល់ឱ្យ
- ចំណូលដែលបានមកពីទ្រព្យសម្បត្តិដែលអនុញ្ញាតដោយរាជរដ្ឋាភិបាល ។

**មាត្រា ២០.-**

ចំណូល និងចំណាយជាប្រចាំ និងជាមូលធនរបស់សាលាភូមិន្ទចៅក្រម ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាលា ។

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់អំពីបែបបទនៃការរៀបចំ ការចាត់ចែង និងការប្រតិបត្តិថវិកា ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំ ការចាត់ចែង និងការប្រតិបត្តិថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២១.-**

ការងារគណនេយ្យរបស់សាលាភូមិន្ទចៅក្រមរួមមាន ÷

- ឯកសារផ្នែកគណនេយ្យទូទៅត្រូវធ្វើជាពីរច្បាប់ ។ ឯកសារនេះ កត់ត្រានូវប្រតិបត្តិការទាំងឡាយផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការផ្នែករតនាគារ និងប្រតិបត្តិការដែលត្រូវធ្វើជាមួយតតិយជន ។
- បញ្ជីសារពើភ័ណ្ឌអចលនទ្រព្យ រូបធាតុ និងវត្ថុមានតម្លៃ ។

ការងារគណនេយ្យរបស់សាលាត្រូវ ÷

- ស្របតាមការកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យដែលយល់ព្រមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២២.-**

គណនេយ្យករ និងអាណាប័កដើមខ្សែ ត្រូវរៀបចំគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីការគ្រប់គ្រង រួចដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចយ៉ាងយូរបំផុត ៣ ខែ បន្ទាប់ពីការបិទការិយបរិច្ឆេទគណនេយ្យ ។

មូលនិធិរបស់សាលាភូមិន្ទចៅក្រម គឺជាប្រាក់សាធារណៈដែលចាំបាច់ត្រូវតែតម្កល់ក្នុងគណនីមួយដែលត្រូវបើកនៅរតនាគារជាតិ លើកលែងតែមានបដិប្បញ្ញត្តិដែលយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## របបសារពើពន្ធនៃសាលាភូមិន្ទចៅក្រម

**មាត្រា ២៣.-**

លើកលែងតែមានបដិប្បញ្ញត្តិរបស់ច្បាប់ សាលាភូមិន្ទចៅក្រម ត្រូវស្ថិតនៅក្រោមនីតិរូប ចំពោះរបបសារពើពន្ធដូចដែលបានអនុវត្តនៅក្នុងអង្គភាពនានារបស់រដ្ឋ ។

## ជំពូកទី ៥
## ការជ្រើសរើសសិស្សឱ្យចូលរៀនសាលាភូមិន្ទចៅក្រម

**មាត្រា ២៤.-**

ការបានចូលរៀននៅសាលាភូមិន្ទចៅក្រម ត្រូវធ្វើដោយការប្រឡង។ ការប្រឡង ២ បែប ត្រូវរៀបចំឡើងតាមសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**មាត្រា ២៥.-**

ការប្រឡងបែបទី ១ គឺត្រូវបើកឱ្យបេក្ខជនដែលមានបរិញ្ញាប័ត្រច្បាប់ ដែលមានអាយុមិនលើសពី ៣០ ឆ្នាំគិតមកដល់ថ្ងៃប្រឡង ។

ចំពោះបេក្ខជនដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រ កម្រិតអាយុអតិបរមា គឺ៣៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។

ការប្រឡងប្រជែងបែបទី ២ គឺត្រូវបើកឱ្យមន្ត្រីរាជការគ្រប់ក្រសួង ដែលមានបរិញ្ញាប័ត្រច្បាប់ និងដែលមានអាយុមិនលើសពី ៤៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។ ចំពោះបេក្ខជន ជាមន្ត្រីរាជការដូចពោលខាងលើដែលបានបំពេញការងារចាប់ពី ៥ ឆ្នាំ ឡើងទៅហើយ បេក្ខជននោះនឹងត្រូវបានទទួលពិន្ទុបន្ថែម ១០ % (ដប់ភាគរយ) ជាមុន នៃពិន្ទុសរុបដែលកំណត់ក្នុងការប្រឡង ។

បេក្ខជនម្នាក់អាចអនុញ្ញាតឱ្យប្រឡងចូលសាលាភូមិន្ទចៅក្រមមិនលើសពី ៣ ដងឡើយ ។

រាជរដ្ឋាភិបាល អាចជ្រើសរើសមន្ត្រីរាជការ ដែលមានបរិញ្ញាប័ត្រច្បាប់ និងដែលមានគុណសម្បត្តិការងារខ្ពស់ ចំនួនប្រាំ (៥ ) រូប ក្នុងជំនាន់នីមួយៗ ឱ្យចូលរៀនក្នុងសាលាភូមិន្ទចៅក្រម ដោយពុំចាំបាច់ឆ្លងកាត់ការប្រឡង ។ ការជ្រើសរើសនេះ ត្រូវតែមានយោបល់យល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាមុន ។

**មាត្រា ២៦.-**

ចំនួនកន្លែងដែលត្រូវយក និងការបែងចែកចំនួនកន្លែងសម្រាប់ការប្រឡងបែបទី ១ និងការប្រឡងបែបទី ២ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីបានពិគ្រោះជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

បែបបទនៃការរៀបចំ វិធានទាក់ទងនឹងវិន័យ និងកម្មវិធីនៃវិញ្ញាសានៃការប្រឡងទាំងពីរបែប ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមមតិរបស់ក្រុមប្រឹក្សាភិបាលសាលា ។



6

**មាត្រា ២៧.-**

កិច្ចការរបស់សិស្សត្រូវមានលក្ខណៈជាអនាមិក និងត្រូវកែពីរលើក ។

**មាត្រា ២៨.-**

គណៈមេប្រយោគនៃការប្រឡងនីមួយៗ ត្រូវវាយតម្លៃដោយឯករាជ្យ នូវចំនួនបេក្ខជនដែលត្រូវឆ្លងកាត់វិញ្ញាសាសម្រេច ។ ក្នុងករណីដែលមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានគណៈមេប្រយោគ ជាសំឡេងដែលមានឧត្តមានុភាព ។

**មាត្រា ២៩.-**

បេក្ខជនដែលបានប្រឡងជាប់ មានឋានៈជាសិស្សចៅក្រម ។ បេក្ខជនដែលមិនមែនជាមន្ត្រីរាជការមុនពេលចូលរៀនត្រូវចុះហត្ថលេខាលើការសន្យាបម្រើរដ្ឋក្នុងរយៈពេល ៧ ឆ្នាំ យ៉ាងតិចគិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង ។

## ជំពូកទី ៦
## ការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម

**មាត្រា ៣០.-**

សាលាភូមិន្ទចៅក្រមជាសាលាអនុវត្ត ។

សិស្សចៅក្រម ត្រូវទទួលការបណ្តុះបណ្តាលបឋមខាងវិជ្ជាជីវៈដែលមានរយៈពេល ២ ឆ្នាំ ។ ការងារបណ្តុះបណ្តាលនេះ រួមមាន ការបង្រៀនឱ្យយល់ដឹងអំពីបច្ចេកទេសខាងតុលាការ និងការត្រិះរិះពិចារណាលើកិរិយកម្មនៃការប្រតិបត្តិខាងវិជ្ជាជីវៈ ។ ការធ្វើកម្មសិក្សានៅសាលាជម្រះក្តី គឺជាផ្នែកមួយយ៉ាងសំខាន់នៃពេលវេលាបណ្តុះបណ្តាល ។

សាលាភូមិន្ទចៅក្រមត្រូវរៀបចំឱ្យមានកម្មវិធីសិក្សាបន្ត និងថ្នាក់វិក្រឹត្យការសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាដែលកំពុងធ្វើកិរិយកម្មនៅសាលាជម្រះក្តី តាមបែបផែនដែលត្រូវកំណត់ដោយបទ បញ្ជាផ្ទៃក្នុង ។

ការបង្រៀនត្រូវធ្វើឡើងដោយ ÷

១.គ្រូបណ្តុះបណ្តាលដែលជាអ្នកច្បាប់ ហើយត្រូវទទួលការបំពាក់បំប៉នផ្នែកគរុកោសល្យ ។ គ្រូបណ្តុះបណ្តាលអាចបំពេញមុខងារជាគ្រូពេញម៉ោង ឬដោយមិនពេញម៉ោង ។

២.អ្នកធ្វើសន្និសីទដែលនាយកសាលាអញ្ជើញមក មួយដងមួយកាល ហើយត្រូវទទួលកម្រៃជា ប្រាក់ម៉ោង ។

**មាត្រា ៣១.-**

បន្ទាប់ពីមានយោបល់ឯកភាពពីក្រុមប្រឹក្សាភិបាល និងពីទីស្តីការគណៈរដ្ឋមន្ត្រី នាយកសាលា ត្រូវចាត់តាំងគ្រូកម្មសិក្សាសម្រាប់រយៈពេល ៣ ឆ្នាំ ឱ្យធ្វើជាអ្នកឆ្លើយឆ្លងរបស់សាលាភូមិន្ទចៅក្រមសម្រាប់ការបណ្តុះបណ្តាល ចៅក្រមក្នុងសាលាជម្រះក្តីទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣២.-**

បទប្បញ្ញត្តិដែលទាក់ទងនឹងរបបនៃរយៈពេលសិក្សា ល័ក្ខខ័ណ្ឌនៃការដាក់ពិន្ទុ និងការធ្វើចំណាត់ថ្នាក់ ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចសម្រាប់សិស្សចៅក្រម ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។

សិស្សចៅក្រមណា ដែលមិនបានបញ្ចប់ការសិក្សា មិនអាចមានលក្ខណសម្បត្តិជាអតីតសិស្សសាលាភូមិន្ទចៅក្រមបានឡើយ ។

**មាត្រា ៣៣.-**

ការចូលរួមក្នុងកិច្ចការទាំងឡាយដែលរៀបចំក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលចៅក្រម ត្រូវបើកទូលាយដល់បុគ្គលទាំងឡាយ ដែលចាប់អារម្មណ៍នឹងកិច្ចការនេះ តាមការសម្រេចរបស់នាយកសាលា ។

**មាត្រា ៣៤.-**

ក្រុមប្រឹក្សាភិបាល ត្រូវបង្កើតគណៈកម្មការវិទ្យាសាស្ត្រ និងគរុកោសល្យ ឱ្យទទួលបន្ទុកផ្តល់យោបល់អំពីកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្តុះបណ្តាលបន្ត និងវិក្រឹត្យការ ។

**មាត្រា ៣៥.-**

គណៈកម្មការវិទ្យាសាស្ត្រ និងគរុកោសល្យមានសមាសភាព ÷

១. នាយកសាលា ........................................ ប្រធាន

២. ជំនាញការនាយកបារាំង ........................................ សហាជិក

៣. នាយកការសិក្សា ........................................ សមាជិក

៤. សាស្ត្រាចារ្យសកលវិទ្យាល័យ ២ រូប ........................................ សមាជិក

៥. ចៅក្រម ២ រូប ........................................ សមាជិក

៦. គ្រូបណ្តុះបណ្តាល ១ រូប ........................................ សមាជិក

៧. បុគ្គលមានសមត្ថភាព ៣ រូប ........................................ សមាជិក

**មាត្រា ៣៦.-**

គណៈកម្មការវិទ្យាសាស្ត្រ និងគរុកោសល្យ ត្រូវប្រជុំមួយឆ្នាំម្តងយ៉ាងតិច តាមការអញ្ជើញរបស់ប្រធានគណៈកម្មការនេះ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាម ភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ហ៊ុន សែន**

***បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី***

***"ដើម្បីសុំហត្ថលេខា"***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាសមាជិកអចិន្ត្រៃយ៍ នៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៨
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង

*****

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ បកចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១១ ខែមករា ឆ្នាំ២០០២

## ស ំ រ េ ច

**មាត្រា ១.-**

កំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មមួយនៅក្នុងភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ឈ្មោះថា តំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង។

**មាត្រា ២.-**

តំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង មានទំហំ ៣៣៦.២៤ ហិកតា។ តំបន់ឧស្សាហកម្មនេះស្ថិតនៅក្នុងខ្សែបន្ទាត់ព្រំ A, B, C, D, E, F, G, H, I, J, K, L, M, N, O, P ហើយនិយាមការនៃចំណុចខ្សែបន្ទាត់ព្រំដីនេះ និង ប្លង់ទីតាំងដីមាននៅក្នុងឧបសម្ព័ន្ធ ដែលជាចំណែកភ្ជាប់ក្នុងអនុក្រឹត្យនេះ។

**មាត្រា ៣.-**

ផ្ទៃដីទាំងអស់ដែលនៅក្នុងបរិវេណតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុងដូចបានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិរបស់រដ្ឋ ហើយបែបបទនៃការរៀបចំ និង នីតិវិធីនៃការគ្រប់គ្រងតំបន់ឧស្សាហកម្មនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤.-**

រាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ព្រមទាំងឯកសារទាំងឡាយណា ដែលពាក់ព័ន្ធនឹងសិទ្ធិលើដីធ្លី ដែលស្ថិតក្នុងតំបន់ឧស្សាហកម្ម ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិង សំណង់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានៈ ប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០០២

## តារាងសម្រង់និយាមការនៃចំនុចព្រំប្រទល់

## តំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង

| ល.រ | X(E) | Y(N) | ល.រ | X(E) | Y(N) |
|---|---|---|---|---|---|
| A | 275447.416 | 1287454.907 | I | 274269.627 | 1290391.330 |
| B | 275505.191 | 1287579.681 | J | 274176.384 | 1290326.579 |
| C | 275739.033 | 1287889.931 | K | 274032.695 | 1290110.221 |
| D | 275561.319 | 1289271.876 | L | 273936.415 | 1289100.759 |
| E | 275371.831 | 1289424.710 | M | 274036.828 | 1288391.130 |
| F | 274909.177 | 1289692.319 | N | 274065.285 | 1288106.150 |
| G | 274869.123 | 1289898.657 | O | 274338.553 | 1288154.008 |
| H | 274397.633 | 1290349.367 | P | 274348.719 | 1287955.143 |

## ប្លង់ទីតាំងដីតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតរាជាយស្វ័យយានកម្ពុជា ជាសហគ្រាសសាធារណៈ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនី នៃសហគ្រាសសាធារណៈ
- យោងតាមលទ្ធផល នៃការប្រជុំអន្តរក្រសួង

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានទំរង់ជាក្រុមហ៊ុនរដ្ឋឈ្មោះ **រាជាយស្ម័យយានកម្ពុជា** សរសេរកាត់ "**អរយក**" ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**អរយក** មានទីស្នាក់ការនៅស្ថានីយ៍ធំភ្នំពេញ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ទីស្នាក់ការនេះ អាចផ្ទេរទៅកន្លែងផ្សេងទៀតតាមការចាំបាច់ ។

**អរយក** គឺជានីតិបុគ្គល មានស្វ័យភាព ផ្នែករដ្ឋបាល បច្ចេកទេស និង ផ្នែកហិរញ្ញវត្ថុ ។

**អរយក** ត្រូវស្ថិតក្រោមឥទ្ធិពល នៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ហើយត្រូវគោរពតាមបទប្បញ្ញត្តិ នៃច្បាប់ ស្តីពីលក្ខន្តិកៈ ទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទប្បញ្ញត្តិ នៃច្បាប់ពាណិជ្ជកម្ម ។

**មាត្រា ២.-**

**អរយក** ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន។

**អរយក** មានគោលដៅ និង ភារកិច្ច ដូចខាងក្រោម :

១- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកទាំងមូលដែលមានស្រាប់ និង ផ្លូវដែកដែលត្រូវបានស្ថាបនាថ្មី ។

២- ជួសជុលថែទាំស្តារពង្រីកបណ្តាញគមនាគមន៍ផ្លូវដែក បណ្តាស្ថានីយ៍ អាគារ ទីលាន ចំណីផ្លូវ ទូរគមនាគមន៍ និង សិក្សាស្រាវជ្រាវលើកគំរោងទិសដៅអភិវឌ្ឍន៍ ។

៣- រ៉ាប់រងសេវាដឹកជញ្ជូនទំនិញ និង អ្នកដំណើរតាមផ្លូវដែក និង សិក្សាស្រាវជ្រាវលើកិច្ចអភិវឌ្ឍន៍វិស័យដឹកជញ្ជូនតាមផ្លូវដែក តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង ទីផ្សារ ។

៤- គ្រប់គ្រង ថែទាំ ជួសជុល បំពាក់ថ្មី មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ បំរើអោយប្រសិទ្ធភាពទាំងបរិមាណ និង គុណភាពនៃសេវាដឹកជញ្ជូន ។

៥- ទទួលខុសត្រូវ និង ទទួលចាត់ចែងលើការងារការពារសណ្តាប់ធ្នាប់ សុវត្ថិភាព សន្តិសុខចរាចរ ខ្សែរថភ្លើង ក្នុងតំបន់គ្រប់គ្រង ។

៦- ប្រកាន់គោលការណ៍ ធ្វើអាជីវកម្មដឹកជញ្ជូនដូចគ្នា នឹង អាជីវករ ។

៧- គ្រប់គ្រងដឹកនាំ និង ចាត់ចែងសកម្មភាពអាជីវកម្មអោយមានប្រសិទ្ធភាព និង ការអភិវឌ្ឍន៍ ។

**មាត្រា ៣.-**

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ **អរយក** ត្រូវគោរពរបបពន្ធ និងអាករស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤.-**

ដើមទុនដំបូងរបស់ **អរយក** ត្រូវកំណត់ឡើងតាមតុល្យការដំបូងដែលបានទទួលនូវការឯកភាពពីក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ពេលដែលអនុក្រឹត្យនេះចូលជាធរមាន **អរយក** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៥.-**

បុគ្គលិករបស់ **អរយក** ត្រូវជ្រើសរើសពីចំណោមមន្ត្រី នៃមុខងារសាធារណៈ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងអាចជ្រើសរើសបុគ្គលិកខាងក្រៅ និង បុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់ ។

បុគ្គលិករបស់ **អរយក** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈ ដោយឡែកអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២

## ការដឹកនាំ និង ការគ្រប់គ្រង

**មាត្រា៦.-**

**អរយក** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិពេញលេញ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ និង លក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| -ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | | ប្រធាន |
| -តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| -តំណាង ក្រសួងសាធារណការ និង ដឹកជញ្ជូន | ០១រូប | សមាជិក |
| -តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| -តំណាង ក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| -តំណាង ក្រសួងពាណិជ្ជកម្ម | ០១រូប | សមាជិក |
| -តំណាង និយោជិតរបស់ **អរយក** | ០១រូប | សមាជិក |

**មាត្រា៧.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្មធ្លាប់បានបំរើការងារយ៉ាងតិច ០៥ឆ្នាំ (ប្រាំឆ្នាំ) ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យបច្ចេកទេស សេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ និង ជំនាញសមមូលផ្សេងទៀត ដែលមានសញ្ជាតិខ្មែរ និង មិនដែលមានទោសឧក្រិដ្ឋ ឬ មជ្ឈឹម ពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទំលាប់ កិត្តិយស និងភាពសុចរិត ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ០៣ ឆ្នាំ ។ អាណត្តិនេះ អាចបញ្ចប់ និង អាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងអោយ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត **អរយក** ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញដើម្បីសំរេចក្នុងនាម **អរយក** ក្នុងការរៀបចំលិខិតស្នាម និង រាល់ឯកសារផ្សេងៗ ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ :**

១-ផ្តល់ការយល់ព្រមលើគំរោងផែនការសហគ្រាសដូចមានចែងក្នុងមាត្រា ១៦ នៃអនុក្រឹត្យនេះ។

២-វាយតំលៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលអោយបានសម ស្របតាមសភាពការណ៍ ។

៣-ផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និង របាយការណ៍ស្តីពីសកម្មភាពរបស់ **អរយក** ។

៤-សំរេចតាមសំណើរបស់ប្រធានអគ្គនាយកនូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្សរ៍ ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិកដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥-ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល **អរយក** ជាភាគីហត្ថលេខីស្របតាមលក្ខខ័ណ្ឌ និងបែប បទដូចមានចែងក្នុងបទបញ្ជាជាធរមាន ។

៦-សំរេចបង្កើតបើក ឬ បិទការិយាល័យ និង ទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ **អរយក** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧-កំណត់លើថ្លៃឈ្នួលពាក់ព័ន្ធ នឹងការធ្វើអាជីវកម្ម សេវាកម្ម ឧស្សាហកម្ម នៃ **អរយក** ។

៨-ផ្តល់ការយល់ព្រមលើសំណើទិញផ្លាស់ប្តូរ ឬលក់ចលនទ្រព្យ និង អចលនទ្រព្យ ព្រមទាំងរាល់សំណើខ្ចីដោយ មានវត្ថុបញ្ចាំ ឬ ការធានាផ្សេងៗ លើទ្រព្យសម្បត្តិរបស់សហគ្រាស ។

**មាត្រា៩.-**

ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេលវេលា អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាសតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិក ចំនួន ០៤ នាក់ យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។ ទោះបីជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាភិបាល ត្រូវធ្វើការប្រជុំយ៉ាងតិច ០១ ដងក្នុងរយៈពេល ០៣ខែ។ ក្នុងករណីប្រធានមានធុរៈត្រូវជ្រើសរើសសមាជិកណាម្នាក់ តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមានដើម្បីដឹកនាំអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអោយបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបានលុះណាតែមានវត្តមានសមាជិកយ៉ាងតិច ០៤នាក់ ។

បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយ ដើម្បីពិភាក្សាឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។

កិច្ចប្រជុំលើកក្រោយនេះ មិនចាំបាច់ទាមទារកូរ៉ុមទេ ។ សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបានលុះណាតែមានការអនុម័តដោយសម្លេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ បើសិនជាការបែកសម្លេងមានចំនួនស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា១០.-**

សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង ទៅមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ១៥ថ្ងៃ យ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយ ហើយត្រូវចំលងចូលបញ្ជីដែលមានលេខរៀង ទំព័រ ជាហូរហែរ និង មានអត្តលេខចំណាំត្រឹមត្រូវ ។ កំណត់ដើមត្រូវបានចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និង សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលមានវត្តមាន និងលេខាធិការជ្រើសរើសដោយប្រធានអគ្គនាយក ។

**មាត្រា១១.-**

ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារប្រក្រតីនៃ **អអឃក** និង ត្រូវបានតែងតាំងសំរាប់អាណត្តិ ០៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។ តំណែងនេះបន្តទៀតបានតាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**មាត្រា១២.-**

ក្រុមប្រឹក្សាភិបាលណែនាំនិងប្រគល់ជូនប្រធានអគ្គនាយក នូវអំណាចចាំបាច់ទាំងឡាយ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ ។

ក្នុងក្របខ័ណ្ឌនេះ ប្រធានអគ្គនាយកមានភារកិច្ច :

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច និងចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលតាមដំណាក់កាលនិមួយៗ។ ប្រធានអគ្គនាយក ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **អអឃក** ។

២-ទទួលដឹកនាំ **អអឃក** ផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម និង ហិរញ្ញវត្ថុ ។

៣-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬ បញ្ឈប់ការងារ និង មានសិទ្ធិត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **អអឃក** ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាន ។

៤-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬ ទាំងអស់រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខា ទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខ័ខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៥-តំណាងអោយ **អអឃក** នឹងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់តវ៉ាការពារក្តីអោយ **អអឃក** និងការប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៣.-**

លាភការក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់ប្រធានអគ្គនាយក ត្រូវកំណត់ដោយក្រសួងអាណាព្យាបាល បច្ចេកទេស និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា១៤.-**

ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ **អអឃក** ត្រូវគោរពតាមបែបបទ និង នីតិវិធីដែលកំណត់ដោយ លក្ខន្តិកៈរបស់សហគ្រាស និង ច្បាប់ជាធរមាន ។

# ជំពូកទី ៣
# ការគ្រប់គ្រង ហិរញ្ញវត្ថុ

**មាត្រា១៥.-**

**អអយក** កាន់កាប់គណនេយ្យរបស់ខ្លួនស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដដែល ។

របាយការណ៍ហិរញ្ញវត្ថុត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី ៣១ ខែ មិនា នៃការិយបរិច្ឆេទបន្ទាប់ ។ របាយការណ៍ហិរញ្ញវត្ថុត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកំឡុងពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខ័ខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា១៦.-**

រៀងរាល់ឆ្នាំមុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាល ត្រូវផ្ដល់ការយល់ព្រមលើគំរោងផែនការរបស់ **អអយក** តាមសំណើរបស់ប្រធានអគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា១៧.-**

ធនធាន នៃ **អអយក** ជាអាទិ៍មាន :

- ដើមទុនដែលរដ្ឋផ្ដល់អោយ ( តុល្យការដំបូងនៅពេលបង្កើត )
-ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពអាជីវកម្មរបស់ **អអយក**
-ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ **អអយក**
-ប្រាក់បានមកពីការខ្ចីបុល ប្រាក់អំណោយ និង ឧបត្ថម្ភធនផ្សេងៗ ។

**មាត្រា១៨.-**

**ចំណាយរបស់ អអយក រួមមាន :**

-ចំណាយប្រក្រតីសំរាប់ដំណើរការ

-ចំណាយវិនិយោគ

-សងបំណុល

-ចំណាយផ្សេងៗ ។

**មាត្រា១៩.-**

**អអយក** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា២០.-**

**អអយក** ត្រូវបង់ប្រាក់ចំណេញប្រចាំឆ្នាំចូលថវិការដ្ឋចំនួន ៣០% (សាមសិបភាគរយ) ហើយរដ្ឋក៏អាចទុកប្រាក់ចំណេញនេះអោយសហគ្រាសផងដែរ ក្នុងករណីដែលរដ្ឋពិនិត្យឃើញថា សហគ្រាសត្រូវធ្វើការអភិវឌ្ឍន៍ចាំបាច់ ។ ប្រាក់ចំណេញដែលនៅសល់ក្រោយពីការបង់ចូលថវិការដ្ឋខាងលើ **អអយក** មានសិទ្ធិប្រើប្រាស់ អោយស្របតាមលក្ខន្តិកៈរបស់សហគ្រាស ។

**មាត្រា២១.-**

រដ្ឋធានាចំពោះបំណុលណាដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ការសាងសង់ និង ជួសជុលធំហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ជាបន្ទុករបស់រដ្ឋ ។

**មាត្រា២២.-**

រយៈពេល ១៥ថ្ងៃយ៉ាងយូរក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **អអយក** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវឯកសារដូចខាងក្រោមនេះ :

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់ **អអយក**
- របាយការណ៍ស្តីពីសកម្មភាពរបាយការណ៍ហិរញ្ញវត្ថុទាំងឡាយរបស់ **អអយក** ។

**មាត្រា២៣.-**

ត្រូវបានដាក់អោយនៅអម **អអយក** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសម្លេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា ១៩-២០-២១ -២២-២៣ និង មាត្រា ២៤ នៃព្រះរាជក្រមលេខ ជ.ស/ រ.ក.ម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២៥

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៤៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ចំនួន ០៤ គ្រឿង ជូនចំពោះនាយកអង្គការទស្សនៈពិភពលោក និង ជំនាញការអង្គការពលកម្មអន្តរជាតិ ដែលមានស្នាដៃល្អក្នុងការជួយជំរុញការងារអភិវឌ្ឍន៍ជនបទចំរុះ និងដើម្បីស្តារហេដ្ឋារចនាសម្ព័ន្ធជនបទ អោយមានការរីកចំរើន ដូចមានរាយនាមខាងក្រោម ÷

១-លោក **ចាស់ស្ទីន បាយវ័ត** ( **Justin Byworth** ) នាយកអង្គការទស្សនៈពិភពលោក

២-លោក **ឌូគ្លេ វីលីងហ្គា** ( **Doekle Wielinga** ) ប្រធានអនុគំរោងការិយាល័យថ្នាក់តំបន់ខេត្តសៀមរាបនៃអង្គការពលកម្មអន្តរជាតិ ( **ILO** )

៣-លោក **សេម៉រ អាល់ ហ្វៃយ៉ាត** ( **Samer AL Fayadh** ) ជំនាញការសាងសង់ និងថែទាំផ្លូវលំនៃអង្គការ **ILO** និង ជាអ្នកសំរបសំរួល **ILO** / វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ( **ITC** )

៤-លោក **ដារ៉ា ជនស្តុន** ( **Dara Johnston** ) ជំនាញការបណ្តុះបណ្តាលបច្ចេកទេសផ្លូវលំ នៃអង្គការ ( **ILO** )

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....៥០....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត /១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## សំរេច

